ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ........................................................

# សុន្ទរកថាថ្លែង
# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងឱកាសពិធីសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆមាសទី១
# និងទិសដៅការងារឆមាសទី២ ឆ្នាំ២០២៤ របស់ធនាគារជាតិនៃកម្ពុជា

**ថ្ងៃសុក្រ ១៤កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨**

**ធនាគារជាតិនៃកម្ពុជា ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៤**

**សូមគោរព៖**

- **គណៈអធិបតី**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីមេត្រី!**

នាពេលនេះ សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០២៤ របស់ធនាគារជាតិនៃកម្ពុជា បានឈានដល់ទីបញ្ចប់ប្រកបដោយជោគជ័យ ក្រោមបរិយាកាសសប្បាយរីករាយ សាមគ្គីភាព និងភាពស្និទ្ធស្នាល។

ខ្ញុំសូមថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំរបស់យើង ដែលបានធ្វើបទអន្តរាគមន៍យ៉ាងក្បោះក្បាយ និងសូមថ្លែងអំណរគុណចំពោះសមាជិក-សមាជិកាអង្គសន្និបាតទាំងអស់ដែលបានចូលរួមក្នុងសន្និបាតនេះ ហើយត្រងត្រាប់ស្តាប់យ៉ាងយកចិត្តទុកដាក់ ក្នុងរយៈពេលពេញមួយថ្ងៃនេះ។ ខ្ញុំជឿជាក់ថា សមាជិក-សមាជិកានៃអង្គសន្និបាតទាំងអស់ពិតជាបានជ្រាបពីសមិទ្ធផលនិងទិសដៅការងារនៅតាមអគ្គនាយកដ្ឋាននិងអង្គភាព ក៏ដូចជាធនាគារជាតិនៃកម្ពុជាទាំងមូល។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៨៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ជាថ្មីម្តងទៀត ខ្ញុំសូមវាយតម្លៃខ្ពស់និងកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និងមន្ត្រី-បុគ្គលិកយើងទាំងអស់ ដែលបានខិតខំបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។ លទ្ធផលដ៏ល្អប្រសើរដែលសម្រេចបាន គឺដោយសារកម្ពុជាមានសុខសន្តិភាព និងស្ថិរភាពនយោបាយដ៏រឹងមាំ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល ដែលមាន **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាប្រមុខ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ជាមួយនឹងអ្វីដែលយើងសម្រេចបាននៅឆមាសទី១នេះ យើងក៏មានការងារជាច្រើនទៀតដែលត្រូវបំពេញ ដើម្បីបន្តរួមចំណែកអភិវឌ្ឍប្រព័ន្ធធនាគារ ក៏ដូចជាសេដ្ឋកិច្ចកម្ពុជាក្រោយវិបត្តិ និងក្នុងស្ថានភាពដែលសេដ្ឋកិច្ចពិភពលោកនិងតំបន់កំពុងប្រឈមនឹងភាពមិនប្រាកដប្រជាខ្ពស់។ នៅក្នុងឆមាសទី២ ឆ្នាំ២០២៤នេះ សេដ្ឋកិច្ចពិភពលោកត្រូវបានមូលនិធិរូបិយវត្ថុអន្តរជាតិព្យាករថាបន្តងើបឡើង ដោយសារសុទិដ្ឋិនិយមនៃកំណើនពាណិជ្ជកម្ម ការប្រើប្រាស់ វិនិយោគ និងទេសចរណ៍។ ទោះយ៉ាងណា ពិភពលោកក៏ប្រឈមនឹងហានិភ័យចម្បងៗផងដែរ ជាពិសេសភាពតានតឹងភូមិសាស្ត្រនយោបាយ ដូចជាការបន្តអូសបន្លាយសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន និងអ៊ីស្រាអែល-ក្រុមហាម៉ាសនៅមជ្ឈិមបូព៌ា ដែលមិនត្រឹមតែអាចផ្តល់ជាបច្ច័យអវិជ្ជមានមកលើលំហូរវិនិយោគផ្ទាល់បរទេស និងការនាំចេញប៉ុណ្ណោះទេ ថែមទាំងអាចជះឥទ្ធិពលលើតម្លៃប្រេងឆៅ ឬធ្វើឱ្យរអាក់រអួលដល់ខ្សែច្រវាក់ផ្គត់ផ្គង់នៃទំនិញនិងសេវា ដែលបង្កភាពមិនច្បាស់លាស់ពីការកើនឡើងវិញនៃអតិផរណា។ម្យ៉ាងទៀត ភាពតានតឹងពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិកនិងចិនក៏អាចនាំឱ្យមានផលប៉ះពាល់លើសេដ្ឋកិច្ចពិភពលោក និងតំបន់ រួមទាំងកម្ពុជាដែលមានការនាំចេញច្រើនទៅសហរដ្ឋអាមេរិក តែនាំចូលច្រើនពីប្រទេសចិន។ ទន្ទឹមនេះ សេដ្ឋកិច្ចចិនក៏ប្រឈមនឹងវិបត្តិអចលនទ្រព្យ កត្តាប្រជាសាស្ត្រ និងការកើនឡើងថ្លៃពលកម្ម ដែលនាំឱ្យប៉ះពាល់ដល់ការងើបឡើងនៃសេដ្ឋកិច្ចតំបន់និងពិភពលោកផងដែរ។

ក្នុងបរិការណ៍នេះ ការនាំចេញនិងការវិនិយោគទៅក្នុងវិស័យកម្មន្តសាលរបស់កម្ពុជាត្រូវបានរំពឹងថានឹងបន្តកើនឡើង តែប្រឈមនឹងហានិភ័យថយចុះ ប្រសិនបើភាពតានតឹង

រវាងសហរដ្ឋអាមេរិកនិងចិនកើនឡើង ហើយកំណើនសេដ្ឋកិច្ចសហភាពអឺរ៉ុបថយចុះ ខុសពីការរំពឹងទុក។ វិស័យទេសចរណ៍នឹងបន្តងើបឡើងថែមទៀត ជាពិសេសតាមផ្លូវអាកាស ដោយសារការតភ្ជាប់ជើងហោះហើរត្រង់ និងភាពប្រសើរឡើងនៃហេដ្ឋារចនាសម្ព័ន្ធក្នុងស្រុក។ ដោយឡែក វិស័យអចលទ្រព្យនឹងបន្តឆ្លងកាត់ដំណាក់កាលកែតម្រូវថ្លៃ ក្នុងពេលដែលការវិនិយោគបរទេសក្នុងវិស័យនេះនៅមានកម្រិតទាប ហើយតម្រូវការក្នុងស្រុកថយចុះ។ កំណើនដ៏ទាបនៃវិស័យអចលនទ្រព្យនឹងធ្វើឱ្យការប្រើប្រាស់ ក៏ដូចជាការវិនិយោគក្នុងស្រុកមានកម្រិតទាបផងដែរ។ ចំណែកឯវិស័យកសិកម្មនៅបន្តមានសក្តានុពលខ្ពស់ក្នុងការរួមចំណែកក្នុងកំណើនសេដ្ឋកិច្ច ជាពិសេសការកែច្នៃកសិផល ការផ្គត់ផ្គង់ទីផ្សារជាតិនិងអន្តរជាតិ និងការធ្វើទំនើបកម្មផលិតកម្ម ក៏ប៉ុន្តែការប្រែប្រួលអាកាសធាតុនៅតែជាហានិភ័យសក្តានុពលមួយចំពោះទិន្នផលកសិកម្ម។ ម្យ៉ាងទៀត ទីផ្សារហិរញ្ញវត្ថុអន្តរជាតិបន្តមានភាពរឹតត្បិតនិងមិនច្បាស់លាស់ ដែលឆ្លុះបញ្ចាំងតាមរយៈកម្រិតខ្ពស់នៃអត្រាការប្រាក់គោលក្នុងប្រទេសអភិវឌ្ឍន៍ និងលំហូរទុនចេញពីប្រទេសកំពុងលូតលាស់។ បញ្ហានេះក៏នឹងបន្តរួមចំណែកធ្វើឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជាបង្កើនភាពប្រុងប្រយ័ត្នទៅលើការផ្តល់ឥណទាន ព្រមទាំងអាចបន្តដាក់សម្ពាធលើអត្រាការប្រាក់នៅកម្ពុជា និងលទ្ធភាពស្វែងរកប្រាក់ចំណេញរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

បញ្ហាបំណុលរបស់អង្គភាពគ្រួសារនិងក្រុមហ៊ុន-សហគ្រាស ដែលដក់សល់ពីវិបត្តិជំងឺកូវីដ-១៩ គួបផ្សំនឹងភាពទន់ខ្សោយនៃកំណើនវិស័យអចលនទ្រព្យ ការជួញដូរដុំនិងរាយ និងការទទួលបានផលទាបជាងការរំពឹងទុកពីវិស័យទេសចរណ៍ ទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់និងកិច្ចសហការដោះស្រាយប្រកបដោយសង្គតិភាព។

ដើម្បីបន្តរួមចំណែករក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងគាំទ្រការងើបឡើងនៃសេដ្ឋកិច្ច ខ្ញុំសូមស្នើឱ្យយកចិត្តទុកដាក់អនុវត្តមុខងារ-ភារកិច្ច ដូចតទៅ ៖

**១/-ការរក្សាស្ថិរភាពថ្លៃ**

អតិផរណាត្រូវបានព្យាករថាមានកម្រិតទាបក្នុងអត្រា ២,៧% នៅឆមាសទី២ និង ១,៥% សម្រាប់ឆ្នាំ២០២៤ទាំងមូល ប៉ុន្តែអាចប្រឈមនឹងភាពមិនច្បាស់លាស់នៃកំណើនថ្លៃម្ហូបអាហារ

ដោយសារការប្រែប្រួលអាកាសធាតុ កំណើនថ្លៃប្រេងនៅពិភពលោក និងការរអាក់រអួលនៃខ្សែច្រវាក់ផ្គត់ផ្គង់សកល ដែលបណ្តាលមកពីការកើនឡើងភាពតានតឹងភូមិសាស្ត្រនយោបាយ។ ឆ្លើយតបនឹងហានិភ័យទាំងនេះ ខ្ញុំសូមស្នើឱ្យ៖

- បន្តតាមដានជាប្រចាំនិងវិភាគឱ្យបានស៊ីជម្រៅលើស្ថានភាពថ្លៃ បច្ច័យដែលបណ្តាលឱ្យមានអតិផរណា និងអតិផរណានៅតាមបណ្តារាជធានី-ខេត្ត
- បន្តរក្សាស្ថិរភាពអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក ដើម្បីរួមចំណែកគ្រប់គ្រងសម្ពាធអតិផរណា តាមរយៈការអនុវត្តនយោបាយរូបិយវត្ថុ និងការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់តាមការចាំបាច់
- សហការជាមួយភាគីពាក់ព័ន្ធ ជាពិសេសក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងវិទ្យាស្ថានជាតិស្ថិតិ ក្នុងការពង្រឹងការគណនា និងការព្យាករអតិផរណាឱ្យកាន់តែប្រសើរឡើង
- ធ្វើទំនើបកម្មក្របខណ្ឌនយោបាយរូបិយវត្ថុ សំដៅពង្រឹងប្រសិទ្ធភាពនយោបាយរូបិយវត្ថុ តាមរយៈការគ្រប់គ្រងអត្រាប្តូរប្រាក់និងអត្រាការប្រាក់ជារៀល
- លើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ដោយសហការជាមួយគ្រប់ភាគីពាក់ព័ន្ធ ដូចជាទៅលើការគាំទ្រការផ្តល់ប្រាក់បៀវត្សរ៍ជារៀល ការផ្តល់ជម្រើសនៃការទូទាត់ជារៀលតាមខេអេចឃ្យូអរនៅតាមបណ្តាហាងទំនិញនិងភោជនីយដ្ឋាននានា និងការទទួលយកប្រាក់រៀលឱ្យកាន់តែទូលំទូលាយថែមទៀត និង
- ធ្វើអង្កេតទំនុកចិត្តធុរកិច្ច ដើម្បីពង្រឹងការវិភាគស្ថានភាពសេដ្ឋកិច្ចឱ្យកាន់តែគ្រប់ជ្រុងជ្រោយ។

## ២/-ការអភិវឌ្ឍប្រព័ន្ធធនាគារ

កាលពីឆ្នាំ២០២៣កន្លងទៅ គ្រឹះស្ថានធនាគារចំនួន៥នៅសហរដ្ឋអាមេរិកនិង១នៅប្រទេសស្វីសបានដួលរលំ ហើយនៅដើមឆ្នាំ២០២៤នេះ ធនាគារសហរដ្ឋអាមេរិក១ទៀតបានដួលរលំ។ ការដួលរលំទាំងនេះ ម្យ៉ាងគឺដោយសារហានិភ័យដែលគ្រឹះស្ថានធនាគារទាំងនេះគរពូន ម្យ៉ាងទៀតគឺដោយសារភាពខ្វះចន្លោះនៃការត្រួតពិនិត្យនិងកម្រិតខ្ពស់នៃអត្រាការប្រាក់គោល។ ការណ៍នេះបង្ហាញថា ការដួលរលំគ្រឹះស្ថានធនាគារអាចកើតឡើង

នៅគ្រប់ទីកន្លែង ទោះបីជានៅក្នុងប្រទេសអភិវឌ្ឍន៍ខ្លាំងក៏ដោយ នៅក្នុងស្ថានភាពដែលវិស័យហិរញ្ញវត្ថុមានភាពមិនប្រាកដប្រជា។ ជាមួយគ្នានេះ នៅពេលដែលកំណើនឥណទានផ្លូវការបានថយចុះ លទ្ធភាពនៃការកើនឡើងការខ្ចីក្រៅផ្លូវការក៏អាចកើនឡើងផងដែរ។ ក្នុងស្ថានភាពនេះ ខ្ញុំសូមស្នើឱ្យ៖

- ពង្រឹងគុណភាពនិងភាពឆាប់រហ័សនៃទិន្នន័យ និងការផ្លាស់ប្តូរទិន្នន័យជាមួយភាគីពាក់ព័ន្ធ ជាពិសេសចំពោះវិស័យដែលប្រឈមនឹងហានិភ័យដែលទាមទារការចូលរួមសហការតាមដាន និងវាយតម្លៃ ដូចជាវិស័យអចលនទ្រព្យ ជាដើម
- វិភាគហានិភ័យនិងធ្វើស្ត្រេសតេស្តទាំងមីក្រូនិងម៉ាក្រូ ដើម្បីវាយតម្លៃពីហានិភ័យនិងទប់ស្កាត់ឱ្យទាន់ពេលវេលា
- ដាក់ឱ្យអនុវត្តនូវបទប្បញ្ញត្តិអនុគ្រោះឱ្យចំគោលដៅនិងមានប្រសិទ្ធភាព ដោយថ្លឹងថ្លែងពីផលប៉ះពាល់ដល់ស្ថិរភាពហិរញ្ញវត្ថុ
- ពង្រីកការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ផ្អែកលើហានិភ័យនិងទស្សនៈអនាគត ជាមួយនឹងការដាក់ចេញវិធានកែតម្រូវឱ្យបានទាន់ពេលវេលា និងប្រសិទ្ធភាព
- សហការជាមួយភាគីពាក់ព័ន្ធដើម្បីប្រឆាំងនឹងការផ្តល់ឥណទានក្រៅផ្លូវការ ដែលជាទូទៅជាប្រភពនៃបំណុលវណ្ឌក និងអាចរាលដាលដល់វិស័យហិរញ្ញវត្ថុផ្លូវការ
- លើកទឹកចិត្តឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្តល់សេវាហិរញ្ញវត្ថុផ្លូវការជូនសាធារណៈជន អាជីវកម្មខ្នាតមីក្រូ តូច និងមធ្យម ឱ្យបានទូលំទូលាយ ដើម្បីរួមចំណែកក្នុងការជំរុញឱ្យវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធវិវត្តជាលំដាប់ទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ ដូចជាការបើកគណនី និងផ្តល់សេវាហិរញ្ញវត្ថុនានា
- ពង្រឹងយន្តការការពារអតិថិជន តាមរយៈការសម្របសម្រួលដោះស្រាយបណ្តឹង តាមលេខទូរស័ព្ទ Hotline ចំនួន ២៦ ខ្សែ (ទីស្នាក់ការកណ្តាល ៥ ខ្សែ)
- បន្តសហការយ៉ាងជិតស្និទ្ធជាមួយអង្គការសហប្រជាជាតិ ទៅលើយន្តការដោះស្រាយបណ្តឹងរបស់អតិថិជន និងការប្រឹក្សាពីបញ្ហាបំណុលនិងស្វែងរកដំណោះស្រាយជម្លោះ
- លើកកម្ពស់ការផ្សព្វផ្សាយចំណេះដឹងហិរញ្ញវត្ថុ សំដៅជំរុញបរិយាបន្ន និង

- លើកទឹកចិត្តឱ្យមានការរួមបញ្ចូលគ្នារវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**៣/-ការធ្វើទំនើបកម្ម និងសមាហរណកម្មប្រព័ន្ធទូទាត់**

ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជំរុញសេដ្ឋកិច្ចនិងសង្គមឌីជីថល ធនាគារជាតិនៃកម្ពុជានឹងបន្តធ្វើទំនើបកម្មប្រព័ន្ធទូទាត់ឱ្យកាន់តែងាយស្រួល សុវត្ថិភាព ឆាប់រហ័ស និងមានសមាហរណកម្មខ្ពស់ទៅក្នុងតំបន់និងពិភពលោក។ ក្នុងទិសដៅនេះ ខ្ញុំសូមស្នើឱ្យ៖

- បន្តធ្វើនវានុវត្តន៍ទៅលើប្រព័ន្ធនិងមធ្យោបាយទូទាត់ឱ្យកាន់តែសម្បូរបែប ស្របតាមតម្រូវការទីផ្សារនិងបច្ចេកវិទ្យា ជាមួយការគ្រប់គ្រងហានិភ័យឱ្យបានរឹងមាំ
- ពង្រឹងប្រព័ន្ធសុវត្ថិភាពលើការគ្រប់គ្រងហានិភ័យសាយប័រ ដោយសហការជាមួយភាគីពាក់ព័ន្ធទាំងជាតិនិងអន្តរជាតិ ជាពិសេស ការពង្រឹងប្រព័ន្ធព័ត៌មានវិទ្យា និងអត្តសញ្ញាណអតិថិជន (KYC) ជាដើម
- បន្តផ្សព្វផ្សាយនិងជំរុញការប្រើប្រាស់ប្រព័ន្ធបាគង ប្រព័ន្ធធនាគារអនឡាញ និងខេអេចឃ្យូអរ ទាំងក្នុងវិស័យឯកជននិងសាធារណៈ
- ពង្រឹងនិងពង្រីកការតភ្ជាប់ប្រព័ន្ធទូទាត់ជាមួយប្រទេសក្នុងតំបន់ និងក្រុមហ៊ុនសេវាទូទាត់អន្តរជាតិនានា និង
- ពន្លឿនការតភ្ជាប់ប្រព័ន្ធទូទាត់បាគងជាមួយក្រុមហ៊ុនទូទាត់ដូចជា VISA និង Master Card ដើម្បីសម្រួលការទូទាត់របស់ភ្ញៀវទេសចរអន្តរជាតិ។

**៤/-ការគាំទ្រហិរញ្ញប្បទានបៃតងនិងប្រកបដោយចីរភាព**

ការកើនឡើងនៃហានិភ័យពីការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់មកលើការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសុខុមាលភាពរបស់ប្រជាជន បានជំរុញឱ្យរដ្ឋាភិបាលនិងស្ថាប័ននានាលើពិភពលោកគិតគូរកាន់តែខ្លាំង អំពីវិធានការបន្សាំ និងការកាត់បន្ថយផលវិបាកពីការប្រែប្រួលអាកាសធាតុ ដែលក្នុងនោះមានការជំរុញការអភិវឌ្ឍហិរញ្ញប្បទានបៃតងនិងប្រកបដោយចីរភាព។

ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព ធនាគារជាតិនៃកម្ពុជានឹងបន្តរួមចំណែកក្នុងការបង្កើតឱ្យមានយន្តការគាំទ្រ និងប្រព័ន្ធអេកូឡូស៊ីចាំបាច់កាន់តែប្រសើរ ដើម្បីជំរុញហិរញ្ញប្បទានបៃតងនិងដោយចីរភាព និងសកម្មភាពជាសារវន្តក្នុងការការពារហានិភ័យបណ្ដាលមកពីការប្រែប្រួលអាកាសធាតុ និងបង្កើតផែនទីមគ្គុទ្ទេសក៍ វដ្ដករសាស្ត្រ និងយន្តការវាយការណ៍សម្រាប់ហិរញ្ញប្បទានប្រកបដោយចីរភាព។ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពកិច្ចការងារនេះ ខ្ញុំក៏សូមស្នើឱ្យ៖

- បន្តលើកកម្ពស់ការកសាងសមត្ថភាព និងចំណេះដឹងដល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ភាគីពាក់ព័ន្ធ និងសាធារណជនទូទៅពីហិរញ្ញប្បទានបៃតងនិងប្រកបដោយចីរភាព និង
- ពង្រឹងក្របខ័ណ្ឌវាយតម្លៃនិងការពារហានិភ័យបណ្ដាលមកពីការប្រែប្រួលអាកាសធាតុរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**៥/-ការពង្រឹងប្រសិទ្ធភាពសេវាធនាគារកណ្ដាល**

ធនាគារជាតិនៃកម្ពុជាជាស្ថាប័នផ្ដល់សេវា ដូច្នេះមន្ត្រី-បុគ្គលិកដែលធ្វើការងារនេះត្រូវមានក្រមសីលធម៌ខ្ពស់និងផ្ដល់សេវាប្រកបដោយភាពឆាប់រហ័សនិងទទួលខុសត្រូវខ្ពស់ ដូចជាការផ្ដល់សេវាគ្រប់គ្រងគណនី សេវាបើកនិងទទួលសាច់ប្រាក់ ជាដើម។ ក្នុងន័យនេះ ខ្ញុំសូមស្នើនាយកដ្ឋានពាក់ព័ន្ធ និងសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ដូចតទៅ៖

- បន្តគ្រប់គ្រងចរាចរណ៍សាច់ប្រាក់ឱ្យមានប្រសិទ្ធភាព ដោយឆ្លើយតបនឹងតម្រូវការដកនិងដាក់សាច់ប្រាក់របស់អតិថិជន
- សម្រួលការប្ដូរក្រដាសប្រាក់ចាស់ ទក់ រហែក ដោយមិនគិតកម្រៃ និង
- លើកកម្ពស់ការប្រើប្រាស់ក្រដាសប្រាក់រៀលដែលមានតម្លៃចារឹកធំៗ ដូចជា ការបើកក្រដាសប្រាក់ ៥ម៉ឺនរៀល និង ១០ម៉ឺនរៀល ឱ្យបានកាន់តែច្រើនទៅក្នុងទីផ្សារ ដោយក្រដាសប្រាក់ទាំងនេះចរាចរនៅមានកម្រិតនៅឡើយ។

## ៦/-ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

កាលពីដើមឆ្នាំ២០២៣កន្លងទៅ កម្ពុជាត្រូវបានដកចេញពីបញ្ជីប្រផេះរបស់ក្រុមការងារហិរញ្ញវត្ថុ FATF។ ជាមួយនឹងការរីកម្រើននៃបច្ចេកវិទ្យា និងការបង្កើតមធ្យោបាយរក្សាតម្លៃ និងទូទាត់ថ្មីៗវិស័យហិរញ្ញវត្ថុនិងធនាគារនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ តែងតែជាគោលដៅនៃការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ ដូច្នេះ ខ្ញុំសូមស្នើឱ្យអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា៖

- បន្តពង្រឹងចំណេះដឹងរបស់ភាគីពាក់ព័ន្ធជាប់ជាប្រចាំ ជាពិសេសបុគ្គលរាយការណ៍ និង
- បន្តពង្រឹងការត្រួតពិនិត្យការអនុវត្តច្បាប់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងកិច្ចសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ទាំងថ្នាក់ជាតិនិងអន្តរជាតិ ដើម្បីឱ្យកម្ពុជាទទួលបានចំណាត់ថ្នាក់កាន់តែប្រសើរឡើង និងចៀសវាងការធ្លាក់ចុះក្នុងបញ្ជីប្រផេះជាថ្មីម្តងទៀត។

## ៧/-ការអភិវឌ្ឍធនធានមនុស្ស

ការអភិវឌ្ឍធនធានមនុស្ស ទាំងទៅលើសមត្ថភាពបច្ចេកទេសនិងជំនាញ ភាពជាអ្នកដឹកនាំ និងគុណធម៌ ជាកិច្ចការងារសំខាន់ដែលត្រូវបន្តធ្វើជាប្រចាំ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការបំពេញមុខងារ-ភារកិច្ចរបស់ធនាគារកណ្តាល ស្របតាមការរីកចម្រើននៃសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជា ការកើនឡើងនៃសមាហរណកម្មទៅក្នុងតំបន់ និងនវានុវត្តន៍យ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ។ ដូចដែល ឯកឧត្តម ទេសាភិបាលកិត្តិយស តែងតែលើកឡើងថា "ដរាបណាខ្ញុំរស់ ខ្ញុំរៀន" ហើយលោក Albert Einstein បានលើកឡើងថា "ជីវិតប្រៀបដូចនឹងការជិះកង់ ដើម្បីឱ្យមានលំនឹង យើងត្រូវធាក់ទៅមុខជានិច្ច"។ ក្នុងន័យនេះ ខ្ញុំសូមស្នើឱ្យ៖

- បន្តរៀបចំនិងកែលម្អគោលនយោបាយគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្ស ដើម្បីធានាឱ្យបាននូវនិរន្តរភាព សុវត្ថិភាព និងប្រសិទ្ធភាពការងារ
- លើកទឹកចិត្តឱ្យមន្ត្រី-បុគ្គលិកយើងបន្តអភិវឌ្ឍចំណេះដឹងជាប្រចាំ និង

- ពង្រឹងការគោរពវិន័យឱ្យបានម៉ឺងម៉ាត់ ដើម្បីធានាបាននូវប្រសិទ្ធភាពការងារ ដូចជា ការគោរពម៉ោងពេលចេញចូលបំពេញការងារ ការប្រើប្រាស់សម្លៀកបំពាក់ឱ្យបានសមរម្យ និងការមិនយកម៉ោងការងារទៅបំពេញកិច្ចការឯកជនផ្សេងៗ។

ខ្ញុំក៏សូមស្នើឱ្យ៖

- សមាគមមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា បន្តរួមចំណែកសម្រាលទុក្ខលំបាករបស់សមាជិកនិងគ្រួសារសមាជិក ក្រោមយន្តការជួយគ្នាទៅវិញទៅមកប្រកបដោយសមភាព
- លើកទឹកចិត្តឱ្យមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា ប្រើប្រាស់ធានារ៉ាប់រងសុខភាពទៅតាមជម្រើសផ្សេងៗ តាមគោលការណ៍ស្ម័គ្រចិត្ត ដែលការទទួលសេវាធានារ៉ាប់រងនេះគឺដើម្បីបំពេញបន្ថែមលើយន្តការឧបត្ថម្ភរបស់សមាគម ជាពិសេសដើម្បីជួយសម្រាលបន្ទុកការចំណាយលើការឈឺថ្កាត់ធ្ងន់ធ្ងរ
- បន្តបង្កើតនូវកម្មវិធីនានា សំដៅពង្រឹងសុខភាព និងសាមគ្គីភាពក្នុងចំណោមមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា និង
- អនុវត្តតាមគោលការណ៍ផ្តល់អាហារូបករណ៍លើថ្លៃសិក្សាចំនួន ១០០% ជូនដល់កូនមន្ត្រី-បុគ្គលិក ដើម្បីសិក្សាថ្នាក់បរិញ្ញាបត្រនៅតាមសាកលវិទ្យាល័យរដ្ឋក្នុងប្រទេសកម្ពុជា និងនៅមណ្ឌលសិក្សាបច្ចេកទេសធនាគារ។

## ៨/- ការពង្រឹងសុវត្ថិភាពការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងប្រព័ន្ធទំនាក់ទំនង

ស្របពេលដែលបច្ចេកវិទ្យាមានការរីកចម្រើន ការទំនាក់ទំនងកាន់តែមានភាពងាយស្រួល ជាពិសេសការប្រើប្រាស់បណ្តាញសង្គម ជាដើម។ ប៉ុន្តែ ភាពងាយស្រួលទាំងនេះក៏បានបង្កជាហានិភ័យផងដែរ ដូចជា ការផ្តល់ព័ត៌មានក្លែងក្លាយ និងការឆបោកនានាដែលបង្កដោយជនឆ្លៀតឱកាស និងឧក្រិដ្ឋជនតាមបច្ចេកវិទ្យា។ ដើម្បីបង្ការនូវហានិភ័យដែលអាចកើតឡើងជាយថាហេតុ ខ្ញុំសូមស្នើឱ្យ ៖

- មន្ត្រី-បុគ្គលិករបស់យើងគោរពគោលការណ៍ណែនាំការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា ដែលចេញផ្សាយដោយនាយកដ្ឋានព័ត៌មានវិទ្យា
- យកចិត្តទុកដាក់លើសុវត្ថិភាពការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងប្រព័ន្ធទំនាក់ទំនង ឱ្យបានខ្ជាប់ខ្ជួន និងប្រើប្រាស់បច្ចេកវិទ្យាទាំងនេះឱ្យចំទិសដៅ
- សម្រាប់ការផ្សព្វផ្សាយព័ត៌មានផ្ទៃក្នុង និងការចែករំលែកទិន្នន័យឬព័ត៌មានដែលទាមទារនូវការរក្សាការសម្ងាត់ យើងគួរប្រើប្រាស់ប្រព័ន្ធ Intranet របស់ធនាគារជាតិនៃកម្ពុជា ដើម្បីការពារហានិភ័យនៃការបែកធ្លាយព័ត៌មាន
- ជួយចែករំលែកព័ត៌មាន និងផ្សព្វផ្សាយគោលនយោបាយ ឬការអនុវត្តការងាររបស់ធនាគារជាតិនៃកម្ពុជា តាមបណ្តាញសង្គមនានា និង
- លើកទឹកចិត្តឱ្យប្រើប្រាស់កម្មវិធីបណ្តាញសង្គម CoolApp ដែលបង្កើតឡើងដោយកូនខ្មែរ ដើម្បីធានាភាពម្ចាស់ការលើការរក្សាការសម្ងាត់ផង និងការដាច់ទំនាក់ទំនងពីប្រព័ន្ធបរទេសផង។

ក្រៅពីនេះ ខ្ញុំសូមស្នើឱ្យ សារៈមន្ទីរសេដ្ឋកិច្ចនិងរូបិយវត្ថុ ព្រះស្រីព្ញសានវ៉្វេន បន្តផ្តល់ការពង្រឹងចំណេះដឹងដល់សាធារណជន ជាពិសេសសិស្សានុសិស្ស អំពីប្រវត្តិសេដ្ឋកិច្ច រូបិយវត្ថុ និងហិរញ្ញវត្ថុនៅកម្ពុជា ដោយសហការជាមួយភាគីពាក់ព័ន្ធដូចជា គ្រឹះស្ថានអប់រំ វិស័យ ទេសចរណ៍ និងវិស័យឯកជននានា។ ខ្ញុំក៏សូមស្នើឱ្យបន្តរៀបចំកម្មវិធីទស្សនកិច្ចសិក្សារបស់សិស្សានុសិស្សទាំងនៅក្នុងរាជធានីភ្នំពេញ និងនៅតាមបណ្តាខេត្ត។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំក៏សូមជម្រាបផងដែរថា មណ្ឌលសិក្សាបច្ចេកទេសធនាគារកំពុងអភិវឌ្ឍទៅជាវិទ្យាស្ថាន ដែលនឹងបើកលទ្ធភាពឱ្យផ្តល់ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រ ចាប់ពីដើមឆ្នាំ២០២៥តទៅ សំដៅចូលរួមអភិវឌ្ឍធនធានមនុស្សក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា។ ខ្ញុំសូមស្នើឱ្យមណ្ឌលសិក្សាបច្ចេកទេសធនាគារពង្រឹងកម្មវិធី និងគុណភាពសិក្សា ពង្រឹងកិច្ចសហការជាមួយគ្រឹះស្ថានឧត្តមសិក្សាទាំងជាតិនិងអន្តរជាតិ និងសម្រេចឱ្យបានការចាប់ផ្តើមថ្នាក់បរិញ្ញាបត្រតាមការគ្រោងទុក។

**- គណៈអធិបតី**

**- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ខ្ញុំជឿជាក់ថា សមាជិក-សមាជិកានៃអង្គសន្និបាតរបស់យើងពិតជាក្តាប់បាននូវខ្លឹមសារសំខាន់ៗនៃលទ្ធផលនិងទិសដៅការងារ ដែលបានលើកឡើងក្នុងអង្គសន្និបាតយើង។ ខ្ញុំសូមស្នើឱ្យថ្នាក់ដឹកនាំតាមបណ្តានាយកដ្ឋាន អង្គភាព និងសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តទាំងអស់ ផ្សព្វផ្សាយបន្តនូវខ្លឹមសារនៃអង្គសន្និបាតរបស់យើងនាពេលនេះ ឱ្យបានទូលំទូលាយដល់មន្ត្រីបុគ្គលិកទាំងអស់ ដើម្បីយល់ច្បាស់ពីទិសដៅរួមរបស់យើងទាំងអស់គ្នា។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា មន្ត្រី-បុគ្គលិកយើងគ្រប់លំដាប់ថ្នាក់ នឹងបន្តឆន្ទៈមោះមុតក្នុងការរួមចំណែកសម្រេចបានសមិទ្ធផលថ្មីៗបន្ថែមទៀត ដើម្បីគាំទ្រការរក្សាស្ថិរភាពម៉ាក្រូ-សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងបន្តអភិវឌ្ឍប្រព័ន្ធធនាគារនៅកម្ពុជា ប្រកបដោយភាពរឹងមាំ និងបរិយាបន្ន ក្នុងស្មារតីរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកម្ពុជា។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ដែលបានអញ្ជើញចូលរួមក្នុងអង្គសន្និបាត សូមជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**ខ្ញុំសូមប្រកាសបិទអង្គសន្និបាតរបស់យើងជាស្ថាពរ។**

**សូមអរគុណ!**